សាស្ត្រាចារ្យ ឈឹម ស៊ុម

# វិធីសម្ពន្ធសង្ខេប

## បែបសម្ពន្ធខ្លី

សិក្ខាវិធីទី ២ ខាងភាសាបាលី

ភ្នំពេញ
ការផ្សាយរបស់ក្រសួងធម្មការ និងសាសនា
ព.ស. ២៥៤៦

# វិធីសម្ពន្ធសង្ខេប

## បែបសម្ពន្ធខ្លី

សិក្ខាវិធីទី ២ ខាងភាសាបាលី


បណ្ឌិតមហា **ឈឹម ស៊ុម** សាស្ត្រាចារ្យ

សាលាបាលីជាន់ខ្ពស់ ក្រុងភ្នំពេញ

រៀបរៀង


**RESUME D'ANALYSE GRAMMATICALE**


par

CHHIM-SOUM

*Professeur de l'Ecole Supérieure de Pali*

à Phnom Penh



បោះពុម្ពឡើងវិញ ចំនួន ៣.០០០ ច្បាប់

ដោយថតចម្លងតាមច្បាប់បោះពុម្ពលើកទី ២ ក្នុងឆ្នាំ ១៩៦៧ របស់អ្នកនិពន្ធ



00009966

បណ្ណាល័យ ហ៊ុន សែន
HUN SEN LIBRARY
R.U.P.P.
សាកលវិទ្យាល័យភូមិន្ទភ្នំពេញ



**ភ្នំពេញ**

ការផ្សាយរបស់ក្រសួងធម្មការ និងសាសនា

គ.ស. ២០០២

# សេចក្តីបញ្ជាក់
# ចំពោះការបោះពុម្ពឡើងវិញ

---

សៀវភៅ " **វិធីសម្ពន្ធសង្ខេប** " នេះ ត្រូវបានបោះពុម្ពឡើងវិញ ក្រោមជំនួយឧបត្ថម្ភរបស់អង្គការសាសនាជប៉ុន ឈ្មោះ រីស្សូកូសី-កៃ (Rissho Kosei-kai " RKK/Japan ") និងកិច្ចសហប្រតិបត្តិការជាមួយអង្គការសន្តិ-ស្ម័គ្រចិត្តជប៉ុន ប្រចាំនៅកម្ពុជា ( Shanti Volunteer Association "SVA/Cambodia" ) ។

ក្រសួងធម្មការ និងសាសនា បានស្នើសុំឱ្យអង្គការសន្តិស្ម័គ្រចិត្តជប៉ុន ប្រចាំនៅកម្ពុជា ជួយបោះពុម្ព និងចែកផ្សាយសៀវភៅនេះ ដើម្បីជាគុណ-ប្រយោជន៍ដល់ :

- ការលើកស្ទួយការអភិវឌ្ឍន៍ពុទ្ធសាសនា នៅកម្ពុជា ។
- ការរក្សាមរតកវប្បធម៌ អក្សរសាស្ត្រ ឱ្យបានគង់វង្ស និងរីកចំរើន ។
- ការពង្រីកចំណេះដឹងទូទៅខាងភាសាបាលី ដែលជាចំណែកមួយជួយទ្រទ្រង់ភាសា អក្សរសាស្ត្រជាតិ និងការប្រតិបត្តិពុទ្ធសាសនា ក្នុងភាពបរិសុទ្ធត្រឹមត្រូវ ក្នុងចំណោមព្រះសង្ឃ និងពុទ្ធមាមកជនទូទៅ ។

ការបោះពុម្ពឡើងវិញនេះ ធ្វើឡើងដោយថតចម្លងតាមច្បាប់ដើម ដែលបោះពុម្ពលើកទី២ ក្នុងឆ្នាំ ១៩៦៧។ អ្នករៀបរៀងអត្ថបទដើម្បីបោះពុម្ពឡើងវិញនេះ បានកែអក្ខរាវិរុទ្ធត្រង់អន្លើខ្លះ តែឃ្លាឃ្លោងរក្សាទុកដដែល ដូចច្បាប់ដើម តែប្រសិនបើមានកំហុសអក្ខរាវិរុទ្ធសេសសល់ត្រង់អន្លើខ្លះទៀត នោះគឺជាលក្ខណៈដែលមានក្នុងច្បាប់ដើមពីមុនមក ។

ក្រសួងធម្មការ និងសាសនា សូមអភ័យទោសជាមុន ចំពោះកង្វះខាតផ្សេងៗ ដែលអាចនឹងកើតមានដោយអចេតនា ក្នុងការបោះពុម្ពឡើងវិញនេះ ។

សូមជនានុជនក្នុងកម្ពុជរដ្ឋ បានចំរើនលូតលាស់ដុះដាលដោយវិជ្ជា និងវិបុលសុខគ្រប់ប្រការ ហើយរួបរួមគ្នាកសាងប្រទេស និងលើកស្ទួយអក្សរសាស្ត្រ និងព្រះពុទ្ធសាសនា ឱ្យបានរីកចំរើនជាភិយ្យោភាព តរៀងទៅ !

សូមថ្លែងអំណរគុណ ប្រកបដោយកតញ្ញូតាធម៌យ៉ាងជ្រាលជ្រៅបំផុត ចំពោះអង្គការ រីស្សូ កូសី-កៃ (RKK/Japan) និងអង្គការសន្តិស្ម័គ្រចិត្តជប៉ុនប្រចាំនៅកម្ពុជា ( SVA/Cambodia ) ដែលបានជួយឧបត្ថម្ភដល់ការបោះពុម្ពសៀវភៅនេះ ។

សូមគោរពជូនមហាកុសលដែលកើតពីធម្មទាននេះ ចំពោះវិញ្ញាណក្ខន្ធរបស់លោកសាស្ត្រាចារ្យ ឈឹម ស៊ុម ដែលជាអ្នករៀបរៀងសៀវភៅនេះ សូមលោកបានទៅសោយសុខនៅសុគតិភព ជានិរន្តរ៍តរៀងទៅ !

ភ្នំពេញ, ខែ កក្កដា ឆ្នាំ ២០០២

ក្រសួងធម្មការ និងសាសនា

## ごあいさつ

この本は、立正佼成会の資金に基づき　シャンティ国際ボランティア会(SVA)により再版されました。

この本が、日本の仏教徒とカンボジアの人々の友情の絆となり、カンボジアの文化発展に貢献できれば幸いです。

## និវេទនកថា

សៀវភៅនេះ ត្រូវបានបោះពុម្ពឡើងវិញ ដោយអង្គការសន្តិស្ម័គ្រចិត្តជប៉ុនប្រចាំកម្ពុជា ( Shanti Volunteer Association " SVA/Cambodia " ) និងដោយមានការឧបត្ថម្ភថវិកាពី

អង្គការ រីស្សូ កូសី-កៃ (RKK/Japan)

យើងខ្ញុំអធិដ្ឋាន សូមឱ្យសៀវភៅនេះបានជាវិភាគទានដល់ការពង្រឹងមិត្តភាពរវាងប្រជាជនកម្ពុជា ជាមួយប្រជាជនជប៉ុន ដែលកាន់សាសនាផ្សេងៗ និងដល់ការថែរក្សាសម្បត្តិវប្បធម៌ និងសម្បត្តិសាសនា របស់ ប្រជាជនកម្ពុជា ។

## ACKNOWLEDGEMENT

This book has been reprinted by Shanti Volunteer Association of Cambodia (SVA/Cambodia) with the financial support from

Rissho Kosei-kai (RKK/Japan)

We pray that this book would contribute to promote the friendship between Cambodian people and Japanese religious people and to preserve Cambodian cultural and religious heritage.

# អារម្ភកថា

វិធីសម្ពន្ធ ជាសិក្ខាវិធីទី ២ ខាងភាសាបាលី ។ ដ្បិតជាអ្នករៀនភាសាបាលីតាមទម្លាប់រៀនមក មុនដំបូងតែងរៀនមេសូត្រទន្ទេញមូលកច្ចាយនៈ ឬកច្ចាយនរូបត្ថកៈ ឬវេយ្យាករណ៍បាលី ដែលជាសិក្ខាវិធីទី ១ ។ បន្ទាប់មកត្រូវតែរៀនវិធីសម្ពន្ធទៀត ដែលជាមេរៀនទី ២ ។ តទៅទៀត ត្រូវរៀនវិធីរៀងប្រយោគបាលីនិងវិធីប្រែបាលីជាសម្រាយ ប្រែសម្រាយជាបាលី តាមសៀវភៅទុកយពាក្យវិលាសិនី ដែលជាសិក្ខាវិធីទី ៣ ។ តទៅទៀតត្រូវរៀនឆន្ទលក្ខណវិធី តាមក្បួនវុត្តោទ័យជាដើម ដែលជាសិក្ខាវិធីទី ៤ ។ ចំពោះវិធីសម្ពន្ធ បើអ្នករៀន ៗ មិនយល់ទេ, ការរៀននោះ នឹងក្លាយទៅជាមិនសូវបានផលល្អ ឬ ឲ្យផលផ្ទុយ គឺទោះបើរៀនគល់ឆ្នាំដ៏ច្រើនយ៉ាងណាក្តី ក៏ប្រែបាលីជាសម្រាយខុសសេចក្តីទទេទៅក៏មាន, ប្រែសម្រាយជាបាលីមិនកើតក៏មាន, តែងសេចក្តីភាសាបាលីមិនត្រូវក៏មាន ព្រោះមិនយល់សម្ពន្ធ មិនដឹងសព្ទណាមានឈ្មោះដូចម្តេច, មិនដឹងបទណាចូលនឹងបទណា ឬមិនដឹងថាក្នុងប្រយោគនីមួយ ៗ ពីត្រឹមណាទៅត្រឹមណាជាមួយរយៈៗសោះ ។

ឯវិធីសម្ពន្ធនោះ មានរបៀបមិនសូវត្រូវគ្នាទេ គឺលោកគ្រូអាចារ្យខ្លះ សម្ពន្ធតាមបែបដែលហៅថា “កយកែវ” គឺក្នុងប្រយោគមួយ ៗ សព្ទណានៅខាងដើម ក៏សម្ពន្ធសព្ទនោះមុន ហើយទើបសម្ពន្ធសព្ទទី ២

ទទួលរងជាលំដាប់ទៅរហូតដល់ចប់ប្រយោគ; លោកគ្រូអាចារ្យខ្លះ សម្ព័ន្ធតាមបែបដែលហៅថា "សម្ព័ន្ធក្នុង ឬ កម្រងផ្កា" គឺក្នុងប្រយោគមួយ ៗ បើមានអាលបនៈនិងនិបាត គឺចាប់សម្ព័ន្ធអាលបនៈមុន រួចចាប់និបាតជាទី ២ ទាញមកភ្ជាប់នឹងកិរិយា ហើយចាប់មកប្រធាន រួចពីនោះស័ព្ទណាប្រែមុនក៏សម្ព័ន្ធមុនរហូតដល់ចប់ប្រយោគ; លោកគ្រូអាចារ្យខ្លះ សម្ព័ន្ធតាមបែបដែលហៅថា "សម្ព័ន្ធញែកធាតុ" របៀបដូចសម្ព័ន្ធក្នុង ប្លែកតែបំបែកកិរិយាស័ព្ទឲ្យដឹងធាតុ, បច្ច័យ, វិភត្តិ, បទ, បុរិសៈ, វចនៈ, កាល, វាចកៈ ប៉ុណ្ណោះ ដូចករោតិ សម្ព័ន្ធថា ករធាតុ ឱ-បច្ច័យ តិវត្តមានាវិភត្តិ បរស្សបទ បឋមបុរិសៈ ឯកវចនៈ ចុះក្នុងបច្ចុប្បន្នកាល ពោលកត្តុដល់... (ជាបទប្រធាន); លោកគ្រូអាចារ្យខ្លះ បើប្រយោគដែលមានអាលបនៈ និបាត ប្រធាន កិរិយាគ្រប់គ្រាន់ នោះលោកសម្ព័ន្ធអាលបនៈជាទី ១ និបាតជាទី ២ ប្រធានជាទី ៣ កិរិយាជាទី ៤ ពោលមករកប្រធាន តពីនោះទៅ ស័ព្ទណានៅខាងដើម ក៏-សម្ព័ន្ធស័ព្ទនោះមុនជាលំដាប់ទៅ រហូតដល់ចប់ប្រយោគ ។

របៀបដើងសម្ព័ន្ធទាំង ៤ បែបនេះ មានពាក្យសម្រាប់ហៅស័ព្ទនិ-មួយ ៗ យ៉ាងវែង យ៉ាងកណ្តាល យ៉ាងខ្លី ដូចស័ព្ទថា បុរិសោ "រីបុរិស" ជាបទប្រធាន ដែលឥតកិរិយាទទួល នោះបើហៅយ៉ាងវែងថា បុរិសោ

ជាបឋមាបធានបទ សុទ្ធបុំលិង្គៈ កត្តុវិសេសយៈ. សការកៈ, បើហៅយ៉ាងកណ្ដាលថា បុរិសោ ជាបឋមាបធានបទ សុទ្ធបុំលិង្គៈ, បើហៅយ៉ាងខ្លីថា បុរិសោ ជាលិង្គៈ ។ ស័ព្ទដទៃទៀតរហូតដល់ពួកនិបាត ក៏មានពាក្យហៅ ៣ យ៉ាង ដូចគ្នាទាំងអស់ ដូច បុរិសោ ច «ពីបុរសក្ដី» ច នោះ បើហៅយ៉ាងវែងថា នេបាតិកបទ ជាបទសមុច្ចយត្ថជោតកៈ យោគដោយ បុរិសោ, បើហៅយ៉ាងកណ្ដាលថា ច ជាបទសមុច្ចយត្ថជោតកៈ យោគដោយ បុរិសោ, បើហៅយ៉ាងខ្លីថា ច ស័ព្ទ បទសមុច្ចយត្ថជោតកៈ ឬបទសមុច្ចយត្ថវាចកៈ ។

ការរៀនភាសាបាលី ត្រឹមតែរបៀបសម្ពន្ធ ១ មុខ ក៏ឃើញថាញ៉ិកញ៉ាក់ម៉្លេះទៅហើយ, ចុះទំពាំបើថែមរបៀបវេយ្យាករណ៍ របៀបតែងសេចក្ដីបាលី របៀបតែងឆន្ទ មកទៀត តើគួរនឹងស្មានថាងាយឬយ៉ាងណា? មិនងាយទេ ។

ហេតុនេះហើយ បានជាចាស់បុរាណ បានចរហាប្រាប់គ្នាថា បើអ្នកឲ្យកូនទៅរៀនបាលីព្រះត្រៃបិដក, ត្រូវអ្នកបណ្ដុះដូង ១ ដើមក្នុងថ្ងៃដែលកូនចេញទៅរៀន, បើដូងនោះបានផ្លែ សឹមសួរកូនថា បានភ្លឺគ្រាន់បើហើយឬនៅ ?

មួយទៀត លោកតែងប្រាប់គ្នាថា កុលបុត្រដែលចង់រៀនបាលីព្រះ

ត្រៃបិដកឲ្យដល់ថ្នាក់ជាអ្នកចេះ នោះត្រូវមានព្យាយាមប្រកបដោយឧ-បាយ ឲ្យដូចបុរសដែលកាត់គល់គគីធំ ១ ទាល់តែដាច់ដោយកាំបិតស្ទាតូចមួយដូច្នោះ ។

ពាក្យទាំងនេះសឲ្យឃើញថា ការរៀនបាលីក្នុងជំនាន់នោះលំបាកណាស់ ព្រោះបែបរៀន ច្រើនតែជាបាលីសុទ្ធ ហើយវែង ១ ពេកផង ។

ដោយហេតុតែសេចក្ដីលំបាកក្នុងការរៀន ចេះតែមានឥតស្រាកដូច្នេះ បានជាខ្លួនខ្ញុំដែលជាអាចារ្យបង្រៀនតាំងពីកាលដែលបង្រៀននៅសាលាបាលីវត្តលង្កាពី ព.ស. ២៤៧៤ គ.ស. ១៩៣១ មកម៉្លេះ តែងគិតរកឧបាយដើម្បីដោះស្រាយឲ្យងាយស្រួលឡើង ទើបគិតដល់ការសិក្សារបស់ខ្លួនពីក្មេង តាំងពីទើបនឹងរៀនមកទល់នឹងបានចេះដឹងប៉ុណ្ណឹងឡើងថា តើកាលដែលរៀនមិនសូវយល់ នោះតើទាស់នឹងអ្វី ? ដែលបានយល់គ្រាន់បើ តើពីត្រឹមណាមក ? ព្រោះរៀនតាមបែបដូចម្ដេច ?

កាលបើបញ្ហានេះកើតឡើងក្នុងចិត្តរឿយ ៗ, សតិសម្បជញ្ញៈរបស់ខ្ញុំដាស់តឿនខ្ញុំឲ្យនឹកឃើញថា ខ្ញុំពីក្មេងកាលជាសាមណេរអាយុ ១២ ឆ្នាំ (ព. ស. ២៤៦២) បានសិក្សាក្នុងសំណាក់លោកគ្រូអាចារ្យគន នៅឃុំពល ស្រុកគងពិសី (កំពង់ស្ពឺ) ដែលជាអ្នកប្រាជ្ញដើមមួយរូបក្នុងជំនាន់នោះ ៗ លោកបានបង្រៀនខ្ញុំឲ្យរៀនមេសូត្រ១០បទ, ឲ្យរៀនតាំងតួ,-ប្រែ,

-សម្ពន្ធ មូលកច្ចាយនៈ ១ ចប់ ៩ ខែ; ឲ្យរៀនប្រែគម្ពីរធម្មបទដ្ឋកថា(ស៊ីករឹត) ខាងបុព្វភាគ ២០ ខែ បច្ឆិមភាគ ២០ ខែ ចប់ក្នុងរយៈវេលា ៤ ឆ្នាំ ។ ខ្ញុំដឹងខ្លួនថា បណ្ដាចំណេះទាំងនេះ ខ្ញុំចេះសេចក្ដីនិទាន និងសេចក្ដីធម៌ក្នុងគម្ពីរធម្មបទ ជាងវិធីសម្ពន្ធ ។ ព្រោះអ្វី? ព្រោះតែខ្ញុំនៅក្មេងចាប់រៀនដំបូង ហើយលោកគ្រូខ្ញុំដែលមានចំណេះច្រើនលើសលុប មានមេត្តាច្រើន ប្រហែលជាចង់ឲ្យខ្ញុំចេះស្មើនឹងលោក បានជាបង្ហូរចំណេះសម្ពន្ធ ដោយឥតសំចៃ ប្រទានដល់ខ្ញុំ គឺលោកបង្រៀនសម្ពន្ធច្រើនបែបពេក ហើយពិស្ដារណាស់ផង ហួសវិស័យប្រាជ្ញាក្មេង ។

ដល់ខ្ញុំមានអាយុ ២០ ឆ្នាំ (ព.ស. ២៤៧០) ខ្ញុំបានរៀនមូលកច្ចាយនៈវេយ្យាករណ៍ និងសម្ពន្ធម្ដងទៀតក្នុងសំណាក់ព្រះតេជព្រះគុណព្រះវិភុញ្ញាណ សោម-ឡូច (មហា ៤ ប្រយោគ) វត្តលង្កា ក្រុងភ្នំពេញ ។ លោកបង្រៀនសម្ពន្ធក្នុងយ៉ាងកណ្ដាលតាមបែបសម្ពន្ធរបស់លោកឧកញ៉ាសុត្តន្តប្រីជាឥន្ទ ។ ខ្ញុំក៏បានចេះសម្ពន្ធគ្រាន់ប្រើ ។

ដល់ខ្ញុំមានអាយុ ២១ ឆ្នាំ (ព.ស. ២៤៧១) ជាសិស្សសាលាបាលីជាន់ខ្ពស់ ក្រុងភ្នំពេញ បានរៀនផ្ទាល់ពីសម្ដេចព្រះមហាសុមេធាធិបតី (ជោតញ្ញាណ ជួន-ណាត) ព្រះសង្ឃរាជ គណៈមហានិកាយ កាលនៅជាព្រះគ្រូសង្ឃសត្ថា សាស្ត្រាចារ្យសាលាបាលីជាន់ខ្ពស់ ។ ព្រះ

មហាថេរេគ្គនេះបានបង្រៀនមូលកច្ចាយនៈ ហើយបានតែងសៀវភៅកច្ចាយនរូបត្ថមកៈយកមកបង្រៀនអមផង បង្រៀនសម្ពន្ធច្រើនបែបផង ហើយមានវគ្គមានស្ទើរល្អណាស់ គឺបង្រៀនពីទូទៅវែងដកបកែខ្ញុំបានយល់គ្រប់បែប ។

សម័យជាមួយគ្នានេះ សម្តេចព្រះធម្មលិខិត លុំ-ឯម កាលជាព្រះញាណបវរវិជ្ជា សាស្ត្រាចារ្យសាលាបាលីជាន់ខ្ពស់ ជានិស្សយាចារ្យផង ជាធម្មាចារ្យផងរបស់ខ្ញុំ បានតាំងខ្ញុំឲ្យបង្រៀនមូលកច្ចាយនៈ កច្ចាយនរូប-ត្ថមកៈព្រមទាំងសម្ពន្ធ ក្នុងសាលាបាលីវត្តលង្កា ដែលមានសិស្សច្រើនបំផុតជាងវត្តទាំងអស់ក្នុងព្រះរាជអាណាចក្រខ្មែរនាសម័យនោះ ។ ខ្ញុំបង្រៀនអស់វេលា ៤ ឆ្នាំ ទើបលោកគ្រូអាចារ្យ អ៊ុក-ជា បង្រៀនតមកទៀត ។ វេលានោះហើយដែលខ្ញុំខំប្រឹងជាទីបំផុត ក្នុងកិច្ចពង្រីកការសិក្សាបាលីតាមរបៀបសម័យថ្មី ដើម្បីឲ្យសិស្សរៀនឆាប់ចេះ ។

កាលដែលខ្ញុំរំពឹងដល់ការសិក្សារបស់ខ្ញុំដូចបានថ្លែងមកនេះ, ខ្ញុំមានយោបល់ថា បណ្ដាសិក្ខាវិធីខាងភាសាបាលីទាំង ៤ មុខគឺ វេយ្យា-ករណ៍បាលី ១ វិធីសម្ពន្ធ ១ ឧភយពាក្យ ១ ឆន្ទលក្ខណវិធី ១, សិក្ខាវិធីមួយ ៗ គួររៀបរៀងជាបី ៗ បែប គឺ បែបសង្ខេប បែបមធ្យម បែបពិស្តារ សម្រាប់អ្នកសិក្សាថ្នាក់បឋមភូមិ មជ្ឈិមភូមិ និងឧត្តមភូមិ ។ ពុំនោះ

ទោត ទឹងរៀបរៀងឲ្យមានបែបជាសៀវភៅសម្រាប់សិស្ស ១ បែប សៀវភៅសម្រាប់គ្រូ ១ បែប ក៏គួរដែរ ។

ដោយហេតុតែខ្ញុំមានយោបល់ដូច្នេះ បានជាខ្ញុំខំរៀបរៀងសៀវ-ភៅសម្រាប់សិស្សបានចប់មុនហើយ ក្នុងចំណោមសិក្ខាវិធី ទាំង ៤ មុខ, លើកតែឆន្ទលក្ខណវិធី ១ ចេញ ខ្ញុំពុំបានធ្វើ ព្រោះអាងថាមានសៀវភៅវុត្តោទ័យ របស់សម្តេចព្រះធម្មលិខិត លី-ឯម ស្រាប់ហើយ ជាបែបខ្លី ៗ គួរដាក់ជាសៀវភៅសម្រាប់សិស្សបាន ។

សៀវភៅ វិធីសម្ពន្ធសង្ខេបនេះ ខ្ញុំបានស្រង់ពាក្យតាំងពីអាយតនិ-បាតជាដើម ក្នុងកច្ចាយនូបត្ថម្ភកៈ មករៀបរៀង ហើយខ្ញុំរៀបរៀងឲ្យប៉ុនគ្នានឹងវិធីសម្ពន្ធបាលីដែលខ្ញុំរៀនពីសំណាក់សម្តេចព្រះមហាសុមេធាធិប-តី ។ ឯសេចក្តីពន្យល់ក្នុងវិធីសម្ពន្ធនោះខ្លះទៀត ខ្ញុំចម្លងពីសៀវភៅវិធីសម្ពន្ធរបស់ព្រះតេជព្រះគុណព្រះវិកខុញ្ញាណ សោម - ឡូច ដែលជាបែបផែនរបស់លោកឧកញ៉ាសុត្តន្តប្រីជាឥន្ទ ។ ដល់មកវេលាដែលបោះពុម្ពសៀវ-ភៅនេះ ខ្ញុំបានយកសៀវភៅសម្ពន្ធមាលា របស់លោកគ្រូអាចារ្យ អ៊ុក-ជា មកផ្ទៀបគ្នាទៀត ។

សូមអរព្រះគុណលោកគ្រូអាចារ្យអ៊ុក-ជា ដែលលោកបានចាត់ការបោះពុម្ពសៀវភៅ សម្ពន្ធមាលា មុនសៀវភៅនេះ ឲ្យខ្ញុំបានសៀវភៅ

នោះ មកជាគូដែកក្នុងវេលាដែលសម្រិតសម្រាំងសៀវភៅនេះផង ។

ក្នុងទីបំផុតនេះ ខ្ញុំសូមគោរពដល់ព្រះគុណធ្ងន់នៃបណ្ឌិតទាំងឡាយ ដូចបានចេញព្រះនាមមកខាងដើមនេះ ហើយខ្ញុំសូមឧទ្ទិសផលដ៏ប្រសើរ ជាឥដ្ឋមនុញ្ញផល ជូន ប្រគេនដល់បណ្ឌិតទាំងឡាយនោះ, សូមឲ្យព្រះគុណបានសមប្រកបដោយវិបុលសុខ និងកិត្តិស័ព្ទ ជាប់អស់កប្បដ៏អង្វែងទៅ ។

សូមឲ្យកុលបុត្រអ្នកសិក្សាទាំងឡាយបានលូតលាស់ដោយអារ្យធម៌សមទ្រង់ជាខ្មែរអ្នកកាន់ពុទ្ធសាសនា កុំឲ្យអវិជ្ជនការគ្របសង្កត់បានឡើយ ។

ភ្នំពេញ នៅថ្ងៃទី ២០ មេសា ១៩៤៨

ព.ស. ២៤៩០

ឈឹម-ស៊ុម

# វិធីសម្ពន្ធខ្មែរ

## បែបសម្ពន្ធថ្មី

កុលបុត្រអ្នកសិក្សាភាសាបាលី គប្បីចេះវិធីសម្ពន្ធ ។ ឯវិធីសម្ពន្ធ ដែលមានសេចក្តីពិស្តារជាអនេក មានរបៀបប្លែក ៗ តាមយោបល់ វេយ្យាករណាចារ្យនោះ កុលបុត្រអ្នកសិក្សាថ្មីមិនងាយនឹងចេះចាំចូលចិត្ត បានក្លាម ៗ ទេ ។ ដើម្បីឲ្យចេះចាំចូលចិត្តងាយ កុលបុត្រគប្បីស្វា-ធ្យាយវិធីសម្ពន្ធសង្ខេប បែបសម្ពន្ធថ្មី ឲ្យចាំមេសម្ពន្ធដែលជាគោលធំ ៗ មាន ២២ មេដូចតទៅ :

### ១–បឋមាវិភត្តិ

បទនាមនាមដែលប្រកបផ្សំនឹងបឋមាវិភត្តិ ត្រង់ដែលប្រែថា "រី" ជាបទប្រធាន មានអត្ថ ៤ យ៉ាងគឺ :

១) បើមិនមានអាខ្យាតកិរិយា ឬកិតកិរិយាទទួលទេ, ហៅថា លិង្គត្ថ ឬលិង្គត្ថបឋមា ឧ. ភិក្ខុនោ ចីវរំ ។ (ប្រែ) ចីវរំ រីចីវរ ភិក្ខុនោ នៃភិក្ខុ ។

(សម្ពន្ធ) ភិក្ខុនោ សាមិសម្ពន្ធៈ ក្នុងចីវរំ ។ លិង្គត្ថៈ ។

២) ដែលមានអាខ្យាតកិរិយា ឬមានកិតកិរិយាទទួល, បើជា កត្តុវាចកៈ, ហៅថា សយកត្តា ឬ សយកត្តុបឋមា សម្ពន្ធចូលនឹងកិរិយា ឧ. ភិក្ខុនោ ចីវរំ អត្ថិ ។ (ប្រែ) ចីវរំ រីចីវរ ភិក្ខុនោ របស់

ភិក្ខុ អត្ថិ មាន ។

(សម្ពន្ធ) ចីវរំ សយកត្តា ក្នុងអត្ថិ ។ អាខ្យាតបទកត្តុវាចកៈ, ភិក្ខុនោ សាមិសម្ពន្ធៈ ក្នុងចីវរំ ។

៣) បើជាហេតុកត្តុវាចកៈ ហៅថា ហេតុកត្តា ឬ ហេតុកត្តុ-បឋមា សម្ពន្ធចូលនឹងកិរិយា ឧ មាតា បុត្តំ ជនេតិ ។ (ប្រែ) មាតា មាតា បុត្តំ ញុំាងកូន ជនេតិ ឲ្យកើត ។

(សម្ពន្ធ) មាតា ហេតុកត្តា ក្នុងជនេតិ ។ អាខ្យាតបទហេតុកត្តុ-វាចកៈ, បុត្តំ ការិតកម្ម ក្នុងជនេតិ ។

៤) បើជាកម្មវាចកៈ ឬ ហេតុកម្មវាចកៈ ហៅថា វុត្តកម្មំ ឬ វុត្តកម្ម-បឋមា សម្ពន្ធចូលនឹងកិរិយា ឧ. (កម្មវាចកៈ) កុសលកម្មំ កាតព្វំ ។ (ប្រែ) កុសលកម្មំ អំពើជាកុសល (គេនបិ គឺអ្នកណាក៏ដោយ) កត្តព្វំ គប្បីធ្វើ ។ ឧ. (ហេតុកម្មវាចកៈ) ព្យត្តេន ភិក្ខុនា បដិពលេន សង្ឃោ ញាបេតព្វោ ។ (ប្រែ) សង្ឃោ សង្ឃ ភិក្ខុនា គឺភិក្ខុ ព្យត្តេន ឈ្លាស បដិពលេន ប្រតិពល ញាបេត-ព្វោ គប្បីឲ្យដឹង ។

(សម្ពន្ធ កម្មវាចកៈ) កុសលកម្មំ វុត្តកម្ម ក្នុង កត្តព្វំ ។ កិតបទកម្ម-វាចកៈ, គេនបិ អនភិហិតកត្តា ក្នុងកត្តព្វំ ។

(សម្ពន្ធ ហេតុកម្មវាចកៈ) សង្ឃោ វុត្តកម្ម ក្នុងញាបេតព្វោ ។ កិតបទហេតុកម្មវាចកៈ, ព្យត្តេននិងបដិពលេន ទាំងពីរបទ វិសេសនៈ របស់ ភិក្ខុនា ។ អនភិហិតកត្តា ក្នុងញាបេតព្វោ ។

## ២–ទុតិយាវិភត្តិ

បទនាមនាមដែលប្រកបផ្សំនឹងទុតិយាវិភត្តិ មានអត្ថ ៦ យ៉ាង សម្ពន្ធ ចូលនឹងកិរិយា ដូច្នេះ :

១) ជាអំពើដែលគេត្រូវធ្វើ ប្រែថា "នូវ" ហៅថា អវុត្តកម្ម ឬ អវុត្តកម្មត្ថទុតិយា ឧ. ជនោ រថំ ករោតិ ។ (ប្រែ) ជនោ ឯជន ករោតិ ធ្វើ រថំ នូវរថ ។

(សម្ពន្ធ ជនោ សយកត្តា ក្នុងករោតិ ។ អាខ្យាតបទ កត្តុវាចកៈ, រថំ អវុត្តកម្ម ក្នុងករោតិ ។

២) ជាដំណើរឬជាទីទៅដល់ ប្រែថា "កាន់" ហៅថា សម្បាបុណិយកម្ម ឬ សម្បាបុណិយកម្មត្ថទុតិយា ឧ. ជនោ គាមំ បាវិសិ ។ (ប្រែ) ជនោ ឯជន បាវិសិ ចូលទៅហើយ គាមំ កាន់ស្រុក ។

(សម្ពន្ធ) ជនោ សយកត្តា ក្នុងបាវិសិ ។ អាខ្យាតបទកត្តុវាចកៈ, គាមំ សម្បាបុណិយកម្ម ក្នុងបាវិសិ ។

៣) ជាទីទទួលសម្រេចនូវអំពើដែលគេប្រើឲ្យធ្វើ ប្រែថា "ញុំាង" ហៅថា ការិតកម្ម ឬ ការិតកម្មទុតិយា ឧ. សុរិយោ លោកំ ឱភាសេតិ ។ (ប្រែ) សុរិយោ ព្រះអាទិត្យ លោកំ ញុំាងលោក ឱភាសេតិ ឲ្យភ្លឺ ។

(សម្ពន្ធ) សុរិយោ ហេតុកត្តា ក្នុងឱភាសេតិ ។ អាខ្យាតបទ ហេតុកត្តុវាចកៈ, លោកំ ការិតកម្ម ក្នុងឱភាសេតិ ។

៤) ជាទីប្រព្រឹត្តទៅរហូតដល់ ឬ លុះដល់ កន្លង រម្លង ប្រែថា "អស់" ហៅថា អច្ចន្តសំយោគ ឬ អច្ចន្តសំយោគទុតិយា ឧ. បុរិសោ យោជនំ គច្ឆតិ ។ (ប្រែ) បុរិសោ បុរស គច្ឆតិ ស្ទុះទៅ យោជនំ អស់មួយយោជន៍ ។

(សម្ពន្ធ) បុរិសោ សយកត្តា ក្នុងគច្ឆតិ ។ អាខ្យាតបទ កត្តុវាចកៈ, យោជនំ អច្ចន្តសំយោគ ក្នុងគច្ឆតិ ។

៥) ជាទីទទួលពាក្យដែលគេនិយាយបំពោះខ្លួន ប្រែថា "នឹង" ឬ "បំពោះ" ហៅថា អកថិតកម្ម ឬ អកថិតកម្មទុតិយា (កាលបើមានបទមួយ ជាអកថិតកម្ម ដូច្នេះ ត្រង់បទមួយដែលប្រែថា "នូវ" ដែលជាអវុត្តកម្មនោះ ត្រឡប់ទៅជា ហៅថា កថិតកម្ម ឬ កថិតកម្មទុតិយាវិញ) ឧ. ភគវន្តំ បញ្ហំ បុច្ឆតិ ។ (ប្រែ) (សោ ភិក្ខុ ភិក្ខុ

នោះ) អវោច បានពោលហើយ ឯតំ (វចនំ នូវពាក្យ) នុ៎ះ ភគវន្តំ នឹងព្រះដ៏មានព្រះភាគ ។

(សម្ពន្ធ) ភិក្ខុ សយកត្តា ក្នុងអវោច ។ អាខ្យាតបទ កត្តុវាចកៈ, សោ វិសេសនៈរបស់ភិក្ខុ, ភគវន្តំ អកថិតកម្ម ក្នុងអវោច, វចនំ កថិតកម្ម ក្នុងអវោច, ឯតំ វិសេសនៈ របស់វចនំ ។

៦) ជាគ្រឿងធ្វើកិរិយាឲ្យមានសេចក្តីប្លែកជាងប្រក្រតី ហៅថា កិរិយាវិសេសនំ ឬ ទុតិយាកិរិយាវិសេសនំ ឧ. បុគ្គលោ ឧទកកីឡំ កីឡិ ។ (ប្រែ) បុគ្គលោ រីបុគ្គល កីឡិ លេងហើយ ឧទកកីឡំ លេងនូវទឹក ។

(សម្ពន្ធ) បុគ្គលោ សយកត្តា ក្នុងកីឡិ ។ អាខ្យាតបទ កត្តុវាចកៈ, ឧទកកីឡំ កិរិយាវិសេសនៈ ក្នុងកីឡិ ។

## ៣–តតិយាវិភត្តិ

បទនាមនាមដែលប្រកបផ្សំនឹងតតិយាវិភត្តិមានអត្ថ ៦ យ៉ាង សម្ពន្ធចូលនឹងកិរិយាក៏មាន ចូលនឹងនិបាតសព្ទគឺសហឬសទ្ធឹក៏មាន ដូច្នេះ :

១) ជាគ្រឿងសម្រេចនូវអំពើ ប្រែថា "ដោយ" ហៅថា ករណំ ឬករណត្ថតតិយា ឧ. កស្សកោ ទាត្តេន ធញ្ញំ លុនាតិ ។ (ប្រែ) កស្សកោ រីអ្នកស្រែ លុនាតិ ច្រូត ធញ្ញំ នូវស្រូវ ទាត្តេន

ដោយកណ្តៀវ ។

(សម្ពន្ធ) កស្សកោ សយកត្តា ក្នុងលុនាតិ ។ អាខ្យាតបទ កត្តុវាចកៈ, ទាត្តេន ករណៈ ក្នុងលុនាតិ, ធញ្ញំ អវុត្តកម្ម ក្នុងលុនាតិ ។

២) ជាផ្លូវ ឬជាទំនង ជាលំនាំ ដែលប្លែកអំពីការសម្រេចនូវអំពើ, ប្រែថា «ដោយនូវ» ឬ «តាម» ហៅថា កិរិយាវិសេសនំ ឬ វិសេសនត្តកិរិយា ឧ. ពុទ្ធោ តបតិ តេជសា ។ (ប្រែ) ពុទ្ធោ ព្រះពុទ្ធ តបតិ រុងរឿង តេជសា ដោយនូវតេជះ ។

(សម្ពន្ធ) ពុទ្ធោ សយកត្តា ក្នុងតបតិ ។ អាខ្យាតបទ កត្តុវាចកៈ, តេជសា កិរិយាវិសេសនៈ ក្នុងតបតិ ។

៣) ជាអ្នកសម្រេចនូវអំពើខ្លួនឯង ក្នុងប្រយោគដែលជាកម្មវាចកៈក៏មាន ក្នុងប្រយោគដែលជាភាវវាចកៈក៏មាន ក្នុងប្រយោគដែលជាហេតុកម្មវាចកៈក៏មាន ប្រែថា «គឺ» ឬ «ដែល» ហៅថា អនភិហិតកត្តា ឬ អនភិហិតកត្តុកិរិយា ឧ. ចិត្តេន នីយតិ លោកោ ។ (ប្រែ) លោកោ សត្វលោក ចិត្តេន គឺចិត្ត នីយតិ ដឹកនាំទៅ ។

(សម្ពន្ធ) លោកោ វុត្តកម្ម ក្នុងនីយតិ ។ អាខ្យាតបទ កម្មវាចកៈ, ចិត្តេន អនភិហិតកត្តា ក្នុងនីយតិ ។

៦) ជាហេតុ ជាចំណង ជាដំណើរ, ប្រែថា "ហេតុ" ឬ "ព្រោះ" ឬ "ព្រោះតែ" ហៅថា ហេតុ ឬ ហេតុតតិយា ឧ. លាភេន ឧន្នតោ លោកោ, អលាភេន ច ឱនតោ ។ (ប្រែ) លោកោ រីសត្វលោក ឧន្នតោ (មានចិត្ត) ខ្ពស់ឡើងហើយ លាភេន ព្រោះលាភ, ច ក៏ (លោកោ រីសត្វលោក) ឱនតោ (មានចិត្ត) ក្រោមចុះហើយ អលាភេន ព្រោះមិនមានលាភ (ឬ) ព្រោះខាតលាភ ។

(សម្ពន្ធ) លោកោ សយកត្តា ក្នុង ឧន្នតោ ៗ កិតបទ កត្តុវាចកៈ, លាភេន ហេតុ ក្នុង ឧន្នតោ; ចសព្ទ វាក្យារម្ភវាចកៈ, លោកោ សយ-កត្តា ក្នុង ឱនតោ ៗ កិតបទ កត្តុវាចកៈ, អលាភេន ហេតុ ក្នុង ឱនតោ ។

៧) ជាអាការ ដូចជាបទវិសេសនៈរបស់បទដែលមានវិភត្តិផ្សេងគ្នា, ប្រែថា "មាន" ហៅថា ឥត្ថម្ភូត ឬ ឥត្ថម្ភូតតតិយា ឧ. មនសា ចេ បទុដ្ឋេន ភាសតិ វា ករោតិ វា ។ (ប្រែ) ចេ បើ (បុគ្គលោ រីបុគ្គល) មនសា មានចិត្ត បទុដ្ឋេន គឺទោសប្រទូស្តហើយ ភាសតិ វា ពោលក្តី ករោតិ វា ធ្វើក្តី ។

(សម្ពន្ធ) ចេសព្ទបរិកប្បត្ថៈ, បុគ្គលោ សយកត្តា ក្នុងភាសតិ ករោតិ, ភាសតិក្តី ករោតិក្តី អាខ្យាតបទ កត្តុវាចកៈ, មនសា ឥត្ថម្ភូត ក្នុង បទុដ្ឋេន ៗ ឥត្ថម្ភូតតតិយា, វាទាំងពីរសព្ទ បទវិកប្បៈ ក្នុងភាសតិ ករោតិ ។

៦) ជាគ្រឿងប្រកបជាមួយ, ប្រែថា ‹‹ដោយ›› ហៅថា សហត្ថ-តតិយា ឧ. សមេតាយស្មា សង្ឃេន សទ្ធិំ (ប្រែ) អាយស្មា រីលោកអ្នកមានអាយុ សទ្ធិំ មួយអន្លើ សង្ឃេន ដោយសង្ឃ សមេតុ ចូរព្រមព្រៀង ។

(សម្ពន្ធ) អាយស្មា សយកត្តា ក្នុង សមេតុ ។ អាខ្យាតបទ កត្តុវាចកៈ, សង្ឃេន សហត្ថតតិយា ក្នុង សទ្ធិំ ។ កិរិយាសមវាយ ក្នុង សមេតុ ។

### ៤– ចតុត្ថីវិភត្តិ

បទនាមនាម ដែលប្រកបផ្សំនឹងចតុត្ថីវិភត្តិមានអត្ថ ៣ យ៉ាងហៅថា សម្បទាន ឬ សម្បទានចតុត្ថី ដូចគ្នាទាំង ៣ យ៉ាង សម្ពន្ធ ចូលនឹងកិរិយាដូច្នេះ :

១) ជាទីឲ្យ ឬ ជាទីទទួលនូវអំណោយ, ប្រែថា ‹‹ដល់›› ឧ. សង្ឃស្ស ទានំ ទេតិ ។ (ប្រែ) (ទាយកោ រីទាយក) ទេតិ ឲ្យ ទានំ នូវទាន សង្ឃស្ស ដល់សង្ឃ ។

(សម្ពន្ធ) ទាយកោ សយកត្តា ក្នុង ទេតិ ។ អាខ្យាតបទ សង្ឃស្ស សម្បទាន ក្នុង ទេតិ, ទានំ អវុត្តកម្ម ក្នុង ទេតិ ។

២) ជាទីបំរុង ជាទីផ្ញើ ឬ ជាទីបញ្ជូន, ប្រែថា ‹‹ដើម្បី›› ឬ ‹‹បំរុង›› ឧ. អាចរិយោ អន្តេវាសិកស្ស បរិក្ខារេ បេសេតិ ។

(ប្រែ) អាចរិយោ អាចារ្យ បោសេតិ ផ្ញើទៅ បរិក្ខារេ នូវគ្រឿងបរិក្ខារទាំងឡាយ អន្តេវាសិកស្ស ដើម្បីកូនសិស្ស ។

(សម្ពន្ធ) អាចរិយោ សយកត្តា ក្នុង បោសេតិ ។ អាខ្យាតបទ កត្តុ-វាចកៈ, អន្តេវាសិកស្ស សម្បទាន ក្នុង បោសេតិ បរិក្ខារេ អវុត្តកម្ម ក្នុង បោសេតិ ។

៣) ជាទីត្រូវគេប្រទូស្ត គេបៀតបៀន, ប្រែថា "ចំពោះ" ឬ "ដល់" ឧ. យោ អប្បទុដ្ឋស្ស នរស្ស ទុស្សតិ ។ (ប្រែ) យោ អ្នកណា ទុស្សតិ ប្រទូស្ត នរស្ស ចំពោះនរៈ អប្បទុដ្ឋស្ស ដែលមិនប្រទូស្ត ។

(សម្ពន្ធ) យោ សយកត្តា ក្នុង ទុស្សតិ ។ អាខ្យាតបទ កត្តុវាចកៈ, អប្បទុដ្ឋស្ស វិសេសនៈ របស់ នរស្ស ។ សម្បទាន ក្នុង ទុស្សតិ ។

## ៥_បញ្ចមីវិភត្តិ

បទនាមនាមដែលប្រកបផ្សំនឹងបញ្ចមីវិភត្តិមានអត្ថ ៣ យ៉ាង ច្រើនតែសម្ពន្ធចូលនឹងកិរិយាដូច្នេះ :

១) ជាដែនចេញ ឬ ជាដែនដែលគេត្រូវវៀរលែង, ប្រែថា "អំពី" ឬ "ចាក" ហៅថា អបាទាន ឬ អបាទានត្ថបញ្ចមី ឧ. បាបា ចិត្តំ និវារយេ ។ (ប្រែ) (បុគ្គលោ បុគ្គល) និវារយេ គប្បីឃាត់ ចិត្តំ

នូវចិត្ត បាបា ចាកបាប ។

(សម្ពន្ធ) បុគ្គលោ សយកត្តា ក្នុង និវារយេ ។ អាខ្យាតបទ កត្តុវាចក:, បាបា អបាទាន: ក្នុង និវារយេ, ចិត្តំ អវុត្តកម្ម ក្នុង និវារយេ ។

២) ជាដែនប្រៀបធៀបឲ្យដឹងថាលើស ឬថយជាងគ្នា, ប្រែថា “ជាង” ហៅថា អបាទាន ឬវិភត្តិអបាទានក្នុងបញ្ចមី ឧ. ទានតោ សីលំ មហប្ផលតរំ ហោតិ ។ (ប្រែ) សីលំ រីសីល មហប្ផលតរំ ហោតិ ជាគុណជាតមានផលច្រើនដោយវិសេស ទានតោ ជាងទាន ។

(សម្ពន្ធ) សីលំ បកតិកត្តា ក្នុង ហោតិ ។ អាខ្យាតបទ កត្តុវាចក:, ទានតោ អបាទាន: ក្នុង ហោតិ, មហប្ផលតរំ វិកតិកត្តា ក្នុង ហោតិ ។

៣) ជាមូលហេតុ គឺជាដើមហេតុដើមចម, ប្រែថា “ហេតុ” ឬ “ព្រោះ” ឬ “ព្រោះតែ” ហៅថា ហេតុ ឬ ហេត្វាបាទានក្នុងបញ្ចមី ឧ. អវិជ្ជាបច្ចយា សង្ខារា (សម្ភវន្តិ) ។ (ប្រែ) សង្ខារ សង្ខារទាំងឡាយ (សម្ភវន្តិ កើតព្រម) អវិជ្ជាបច្ចយា ព្រោះសេចក្តីល្ងង់ជាបច្ច័យ ។

(សម្ពន្ធ) សង្ខារា សយកត្តា ក្នុង សម្ភវន្តិ ។ អាខ្យាតបទ កត្តុវាចក:, អវិជ្ជាបច្ចយា ហេតុ ក្នុង សម្ភវន្តិ ។

## ៦–ឆដ្ឋីវិភត្តិ

បទនាមនាមដែលប្រកបទៅនឹងឆដ្ឋីវិភត្តិមានអត្ថ ៦ យ៉ាង សម្ពន្ធចូលបានកែទីនឹងនាមនាម ដូច្នេះ :

១ ) ជាគ្រឿងជាប់ដោយម្ចាស់របស់, ប្រែថា "នៃ" ឬ "របស់" ហៅថា សាមិសម្ពន្ធ ឬ សាមិសម្ពន្ធឆដ្ឋី ឧ. ភិក្ខុនោ បត្តចីវរំ ។ (ប្រែ) បត្តចីវរំ គឺបាត្រនិងចីវរ ភិក្ខុនោ របស់ភិក្ខុ ។

(សម្ពន្ធ) ភិក្ខុនោ សាមិសម្ពន្ធៈ ក្នុង បត្តចីវរំ ។ លិង្គត្ថៈ ។

២ ) ជាគ្រឿងជាប់ដោយពួក ដោយក្រុម, ប្រែថា "នៃ" ហៅថា សមុហសម្ពន្ធ ឬ សមុហសម្ពន្ធឆដ្ឋី ឧ. សកុណានំ សង្ឃោ ។ (ប្រែ) សង្ឃោ ពួក សកុណានំ នៃសត្វស្លាបទាំងឡាយ ។

(សម្ពន្ធ) សកុណានំ សមុហសម្ពន្ធៈ ក្នុង សង្ឃោ ។ លិង្គត្ថៈ ។

៣ ) ជាគ្រឿងជាប់ដោយការស័ព្ទជាដើម, ប្រែថា "នៃ" ហៅថា កាកទិសម្ពន្ធ ឬ កាកទិសម្ពន្ធឆដ្ឋី ឧ. អត្ថស្ស ទុន្នយតា ។ (ប្រែ) អត្ថស្ស ទុន្នយតា ភាវៈ នៃអត្ថ គឺកុលបុត្រគប្បីដឹងបានដោយកម្រ ។

(សម្ពន្ធ) អត្ថស្ស កាកទិសម្ពន្ធៈ ក្នុង ទុន្នយតា ។ លិង្គត្ថៈ ។

៤ ) ជាសេចក្ដីដែលចូលមកប្រហែលដូចជាបទប្រធានដោយឡែក, ប្រែថា "កាល" ថា "កាលបើ" ឬ "កាលដែល" ហៅថា អនាទរ

ឬ អនាទរឆដ្ឋី ឧ. រុទតោ ទារកស្ស, បិតា និក្ខមិត្វា បព្វជិ ។ (ប្រែ) ទារកស្ស កាលដែលទារក រុទតោ កំពុងយំ, បិតា របិតា និក្ខមិត្វា ចេញទៅហើយ បព្វជិ បួសហើយ ។

(សម្ពន្ធ) ទារកស្ស អនាទរៈ ក្នុង រុទតោ ។ អនាទរកិរិយា, បិតា សយកត្តា ក្នុង បព្វជិ ។ អាខ្យាតបទ កត្តុវាចកៈ, និក្ខមិត្វា បុព្វកាលកិរិយា ក្នុង បព្វជិ ។

៥) ជាសេចក្តីដកញែកចេញឲ្យដាច់ដោយឡែក អំពីចំនួនដែល-រួម ដែលប្រមូលគ្នា, ប្រែថា “ដ៏នូ” ឬ “បណ្តា” ហៅថា និទ្ធារណំ(១)ឬ និទ្ធារណឆដ្ឋី ឧ. មនុស្សានំ ខត្តិយោ សូរតមោ ។ (ប្រែ) មនុស្សានំ បណ្តាមនុស្សទាំងឡាយ ខត្តិយោ ក្សត្រ សូរតមោ ក្លៀវក្លា បំផុត ។

(សម្ពន្ធ) មនុស្សានំ និទ្ធារណៈ ក្នុង ខត្តិយោ ។ និទ្ធារណីយៈ របស់

---

១ និទ្ធារណៈមានពីរ គឺ ឆដ្ឋីនិទ្ធារណៈ ១ សត្តមីនិទ្ធារណៈ ១ គឺត្រង់ដែលប្រែថា “ដ៏នូទាំងឡាយ, បណ្តាទាំងឡាយ” ផ្នែកខាងពហុវចនៈ ទាំងពីរវិភត្តិ ។ កាលបើមាននិទ្ធារណៈហើយ, រមែងមាននិទ្ធារណីយៈ ទទួលរងជាធិកប ។ ឯនិទ្ធារណីយៈ មាន ៧ គឺ បឋមានិទ្ធារណីយៈ, ទុតិយា..., តតិយា..., ចតុត្ថី..., បញ្ចមី..., ឆដ្ឋី..., សត្តមី... ។

មនុស្សក្លាន់ និងជាលិង្គត្ថៈ, សូរតោ វិសេសនៈ របស់ ទត្តោ ។

៦) ជាបទកម្ម គឺជាអំពើដែលគេត្រូវធ្វើ (ចុះជំនួសទុតិយាវិភត្តិ) សម្ពន្ធចូលទីនឹងបទដែលជាកិតនាម, ប្រែថា "នូវ" ហៅថា ឆដ្ឋីកម្ម ឬ កម្មត្ថឆដ្ឋី ឧ. ចិត្តស្ស ទមថោ សាធុ ។ (ប្រែ) ទមថោ កិរិយាទូន្មាន ចិត្តស្ស នូវចិត្ត សាធុ ជាការប្រពៃ ។

(សម្ពន្ធ) ចិត្តស្ស ឆដ្ឋីកម្ម ក្នុង ទមថោ, សាធុ វិសេសនៈ របស់ ទមថោ ។ លិង្គត្ថៈ ។

## ៧– សត្តមីវិភត្តិ

បទនាមនាម ដែលប្រកបដោយទីនឹងសត្តមីវិភត្តិមានអត្ថ ៩ យ៉ាង សម្ពន្ធចូលទីនឹងកិរិយាក៏មាន ចូលទីនឹងនាមក៏មាន ដូច្នេះ :

១) ជាទីតាំង, ប្រែថា "ក្នុង" ហៅថា បដិច្ឆន្នាធារោ ឬ បដិច្ឆន្នាធារត្ថសត្តមី ឧ. អន្តោគេហេ និសីទតិ ។ (ប្រែ) (សោ រត) និសីទតិ អង្គុយ អន្តោគេហេ ក្នុងខាងក្នុងនៃបន្ទប់ ។

(សម្ពន្ធ) សោ សយកត្តា ក្នុង និសីទតិ ។ អាខ្យាតបទ កត្តុវាចកៈ, អន្តោគេហេ បដិច្ឆន្នាធារៈ ក្នុង និសីទតិ ។

២) ជាទីជ្រកជ្រាប ឬ លាយគ្នា, ប្រែថា "ក្នុង" ហៅថា ព្យាបិកាធារោ ឬ ព្យាបិកាធារត្ថសត្តមី ឧ. ជលេ ខីរំ តិដ្ឋតិ ។ (ប្រែ)

ខីរំ ទឹកដោះស្រស់ តិដ្ឋតិ ស្ថិតនៅ ជលេ ក្នុងទឹក ។

(សម្ពន្ធ) ខីរំ សយកត្តា ក្នុង តិដ្ឋតិ ។ អាខ្យាតបទ កត្តុវាចកៈ, ជលេ ព្យាបិកាធារៈ ក្នុង តិដ្ឋតិ ។

៣) ជាទីនៅអាស្រ័យ ប្រែថា "ក្នុង" ហៅថា វេសយិកាធារោ ឬ វេសយិកាធារត្ថសត្តមី ឧ. ជលេ មច្ឆា វសន្តិ ។ (ប្រែ) មច្ឆា ត្រីទាំងឡាយ វសន្តិ នៅ ជលេ ក្នុងទឹក ។

(សម្ពន្ធ) មច្ឆា សយកត្តា ក្នុង វសន្តិ ។ អាខ្យាតបទ កត្តុវាចកៈ, ជលេ វេសយិកាធារៈ ក្នុង វសន្តិ ។

៤) ជាកាល ជាពេល, ប្រែថា "ក្នុង" ហៅថា កាលសត្តមី ឬ កាលត្ថសត្តមី ឧ. យស្មឹ សមយេ កាមាវចរំ កុសលចិត្តំ ឧប្បន្នំ ហោតិ ។ (ប្រែ) កុសលចិត្តំ កុសលចិត្ត កាមាវចរំ ជាកាមាវចរ ឧប្បន្នំ ជាចិត្តកើតឡើងហើយ ហោតិ មាន សមយេ ក្នុងសម័យ យស្មឹ ឯណា ។

(សម្ពន្ធ) កុសលចិត្តំ បកតិកត្តា ក្នុង ហោតិ ។ អាខ្យាតបទ កត្តុវាចកៈ, យស្មឹ វិសេសនៈ របស់ សមយេ ។ កាលត្ថសត្តមី ក្នុង ហោតិ, កាមាវចរំ វិសេសនៈ របស់ កុសលចិត្តំ, ឧប្បន្នំ វិកតិកត្តា ក្នុង ហោតិ ។

៥) ជាទីរង ជាទីទ្រ ឬជាទីជាប់ ជាទីជ្រៀតជ្រែក, ប្រែថា "លើ"

ជា "ឰដ៏" ជា "ច្រើន" ឬ "នោះ" ហៅថា ឧបសិលេសិកាធារក ឬ ឧបសិ-លេសិកាធារត្ថសត្តមី ឧ. ភគវា បញ្ញត្តេ អាសនេ និសីទិ ។ (ប្រែ) ភគវា គឺព្រះដ៏មានព្រះភាគ និសីទិ គង់ហើយ អាសនេ លើអាសនៈ បញ្ញត្តេ ដែលគេក្រាលហើយ ។

(សម្ពន្ធ) ភគវា សយកត្តា ក្នុង និសីទិ ។ អាខ្យាតបទ កត្តុវាចកៈ, បញ្ញត្តេ វិសេសនៈ របស់ អាសនេ ។ ឧបសិលេសិកាធារៈ ក្នុង និសីទិ ។

៦) ជាសេចក្តីជ្រែកចូលមក ដូចជាបទប្រធានដោយឡែក, ប្រែថា "នាកាល" ថា "កាលបើ" ឬ "កាលដែល" ហៅថា លក្ខណំ ឬ លក្ខណវន្តំ ឧ. សុរិយេ អត្ថង្គតេ, ចន្ទោ ឧគ្គច្ឆតិ ។ (ប្រែ) សុរិយេ នាកាលព្រះអាទិត្យ អត្ថង្គតេ អស្តង្គតហើយ, ចន្ទោ គឺព្រះចន្ទ ឧគ្គច្ឆតិ រះឡើង ។

(សម្ពន្ធ) សុរិយេ លក្ខណៈ ក្នុង អត្ថង្គតេ ។ លក្ខណកិរិយា, ចន្ទោ សយកត្តា ក្នុង ឧគ្គច្ឆតិ ។ អាខ្យាតបទ កត្តុវាចកៈ ។

៧) ជាគ្រឿងចំណាំ ឬ ជាហេតុ, ប្រែថា "និមិត្ត" ហៅថា និមិត្តសត្តមី ឧ. កុញ្ជរោ ទន្តេសុ ហញ្ញតេ ។ (ប្រែ) កុញ្ជរោ គឺដំរី(គេន គឺគេ) ហញ្ញតេ សម្លាប់ ទន្តេសុ និមិត្តក្នុងភ្លុកទាំងឡាយ ។

(សម្ពន្ធ) កុញ្ជរោ វុត្តកម្ម ក្នុង ហញ្ញតេ ។ អាខ្យាតបទ កម្មវាចកៈ,

តេន អនភិហិតកត្តា ក្នុង ហញ្ញតេ, ខេត្តេសុ និមិត្តសត្តមី ក្នុង ហញ្ញតេ ។

៨) ជាសេចក្ដីដកញែកចេញឲ្យដាច់ដោយឡែក អំពីចំនួនដែលរួម ដែលប្រមូលគ្នា, ប្រែថា "ដំណុំ" ឬ "បណ្ដា" ហៅថា និទ្ធារណំ ឬនិទ្ធារណ-សត្តមី ឧ. តេសុ ទ្វីស្វេកោ សោតាបត្តិផលំ បាបុណិ ។

(ប្រែ) តេសុ ទ្វីសុ (ភិក្ខូសុ បណ្ដាភិក្ខុទាំងឡាយ) ពីររូប នោះ (ភិក្ខុ រី ភិក្ខុ) ឯកោ មួយរូប បាបុណិ ដល់ហើយ សោតាបត្តិផលំ នូវសោតា-បត្តិផល ។

(សម្ពន្ធ) តេសុ ទ្វីសុ ទាំងពីរបទ វិសេសនៈរបស់ភិក្ខូសុ ៗ និទ្ធារ-ណៈ ក្នុង ឯកោ ភិក្ខុ, ឯកោ វិសេសនៈរបស់ភិក្ខុ ៗ និទ្ធារណីយៈរបស់ភិក្ខូ-សុ និងជាសយកត្តា ក្នុង បាបុណិ ៗ អាខ្យាតបទ កត្តុវាចកៈ, សោតាបត្តិ-ផលំ អវុត្តកម្ម ក្នុង បាបុណិ ។

៩) ជាទីជិត ជាទីប្រប, ប្រែថា "ជិត" ឬ "ទៀប" ហៅថា សមីបា-ធារៈ ឬ សមីបាធារត្ថសត្តមី ឧ. សាវត្ថិយំ វិហរតិ ជេតវនេ ។

(ប្រែ) (ភគវា រីព្រះដ៏មានព្រះភាគ) វិហរតិ គង់នៅ ជេតវនេ ក្នុងវត្តជេតពន សាវត្ថិយំ ជិតក្រុងសាវត្ថី ឬ ទៀបក្រុងសាវត្ថី ។

(សម្ពន្ធ) ភគវា សយកត្តា ក្នុង វិហរតិ ៗ អាខ្យាតបទ កត្តុវាចកៈ, សាវត្ថិយំ សមីបាធារៈ ក្នុង វិហរតិ, ជេតវនេ វេសយិកាធារៈ ក្នុង វិហរតិ ។

## ៨–អាលបនៈ

បទនាមនាមដែលប្រកបផ្សំនឹងបឋមាវិភត្តិ គ្រង់ដែលប្រែថា "បពិត្រ, ម្នាល, នែ, ហៃ" ហៅថា អាលបនំ មានពីរយ៉ាង គឺ :

១) ដែលពោលដោយសេចក្ដីគោរព, ប្រែថា "បពិត្រ" ហៅថា សគារវាលបនំ ឬហៅត្រឹមតែ អាលបនំ ក៏បាន ឧ. ជយតុ ភវំ មហារាជ ។ (ប្រែ) មហារាជ បពិត្រមហារាជ ភវំ ព្រះអង្គចំរើន ជយតុ សូមទ្រង់ឈ្នះ ។

(សម្ពន្ធ) មហារាជ សគារវាលបនៈ, ភវំ សយកត្តា ក្នុង ជយតុ ៗ អាខ្យាតបទ កត្តុវាចកៈ ។

២) ដែលពោលដោយមិនមានសេចក្ដីគោរព, ប្រែថា "ម្នាល, នែ, ហៃ" ហៅថា អគារវាលបនំ ឬហៅត្រឹមតែ អាលបនំ ក៏បាន ឧ. ធម្មំ វោ ភិក្ខវេ ទេសិស្សាមិ ។ (ប្រែ) ភិក្ខវេ ម្នាលភិក្ខុទាំងឡាយ (អហំ តថាគត) ទេសិស្សាមិ នឹងសំដែង ធម្មំ នូវធម៌ វោ ដល់អ្នកទាំងឡាយ ។

(សម្ពន្ធ) ភិក្ខវេ អគារវាលបនៈ, អហំ សយកត្តា ក្នុង ទេសិស្សាមិ ៗ អាខ្យាតបទ កត្តុវាចកៈ, ធម្មំ អវុត្តកម្ម ក្នុង ទេសិស្សាមិ, វោ សម្បទានៈ ក្នុង ទេសិស្សាមិ ។

## ៩-គុណនាម

បទដែលជាគុណនាមមានអត្ថ ៤ យ៉ាងដូច្នេះ :

១) ជាគ្រឿងធ្វើនាមនាមឲ្យមានសេចក្តីប្លែកជាងប្រក្រតី ហៅថា "វិសេសនំ" ឬ "តុល្យាធិករណវិសេសនៈ" ឧ. អគ្គោ ពុទ្ធោ ។ (ប្រែ) ពុទ្ធោ ព្រះពុទ្ធ អគ្គោ ដ៏ប្រសើរ ។

(សម្ពន្ធ) អគ្គោ វិសេសនៈ របស់ ពុទ្ធោ ១ លិង្គត្ថៈ ។

២) ជាគុណនាមសុទ្ធក្តី ជានាមនាម តែយកមកប្រើដូចជាគុណ-នាមក្តី ដែលចូលនឹងកិរិយាស័ព្ទ ប្រែថា "មាន" ថា "កើត" ថា "ជា" ហៅថា វិកតិកត្តា ឬ វិកតិកត្តុបឋមា; (កាលបើមានបទមួយជាវិកតិកត្តាដូច្នេះ ត្រង់បទមួយដែលប្រែថា "រឺ" ដែលជាសយកត្តានោះ ត្រឡប់ទៅជាហៅថា បកតិកត្តា ឬបកតិកត្តុបឋមាវិញ) ឧ. អប្បស្សុតោ ហោតិ ។ (ប្រែ) បុរិសោ បុរស អប្បស្សុតោ ហោតិ ជាអ្នកមានពុទ្ធវចនៈមានប្រមាណតិចស្តាប់ហើយ ។

(សម្ពន្ធ) បុរិសោ បកតិកត្តា ក្នុង ហោតិ ១ អាខ្យាតបទកត្តុការកៈ, អប្បស្សុតោ វិកតិកត្តា ក្នុង ហោតិ ។

៣) បទវិសេសនៈ ដែលប្រកបដោយបឋមាវិភត្តិ ក្នុងប្រយោគដែលជាកម្មវាចកៈ ហៅថា វិកតិវុត្តកម្ម ឬវិកតិវុត្តកម្មបឋមា ឧ. ចាណា.

តិបាតកម្មស្ស តេ ភន្តេ អការកោ ការកោ ។ (ប្រែ) ភន្តេ បពិត្រព្រះអង្គដ៏ចំរើន (កុក្កុដមិត្តោ ឯនេសាទឈ្មោះកុក្កុដមិត្ត) តេ គឺព្រះអង្គ ការកោ ទ្រង់ធ្វើហើយ អការកោ ឲ្យជាអ្នកមិនធ្វើ បាណា-តិបាតកម្មស្ស នូវបាណាតិបាតកម្ម (ឬ?) ។

(សម្ពន្ធ) ភន្តេ អាលបនៈ, កុក្កុដមិត្តោ បកតិវុត្តកម្ម ក្នុង ក-កោ ។ កិតបទ កម្មវាចកៈ, បាណាតិបាតកម្មស្ស ឆដ្ឋីកម្ម ក្នុង អការ-កោ ។ វិកតិវុត្តកម្ម ក្នុង ការកោ, តេ អនភិហិតកត្តា ក្នុង ការកោ ។

៤) បទវិសេសនៈ ដែលប្រកបដោយទុតិយាវិភត្តិ ចូលជាមួយនឹងកិរិយាអាខ្យាតថា ‹‹ធ្វើ›› ជាកត្តុវាចកៈ ហៅថា វិកតិអវុត្តកម្ម ឬ វិកតិអវុត្តកម្មតទុតិយា; (កាលបើមានបទមួយជា វិកតិអវុត្តកម្ម ដូច្នេះ ត្រង់បទមួយដែលប្រែថា ‹‹នូវ›› ដែលជា អវុត្តកម្ម នោះ ត្រូវប្រែទៅជា ហៅថា បកតិអវុត្តកម្ម ឬ បកតិអវុត្តកម្មតទុតិយាវិញ) ឧ. ឥមំ អត្ថំ បាកដំ ករោហិ ។ (ប្រែ) (ត្វំ អ្នក) ករោហិ ចូរធ្វើ អត្ថំ នូវសេចក្តី ឥមំ នេះ បាកដំ ឲ្យប្រាកដ ។

(សម្ពន្ធ) ត្វំ សយកត្តា ក្នុងករោហិ ។ អាខ្យាតបទ កត្តុវាចកៈ, ឥមំ វិសេសនៈរបស់ អត្ថំ ។ បកតិអវុត្តកម្ម ក្នុង ករោហិ, បាកដំ វិកតិអវុត្ត-កម្ម ក្នុង ករោហិ ។

## ១០–សព្វនាម

បទដែលជាសព្វនាមមានអត្ថ ២ យ៉ាងគឺ :

១) បើជាបុរិសសព្វនាម សម្ពន្ធជួបបទនាមនាម: "ត" ដែលប្រែថា "ព្រះអង្គ" ឧ. ស្វេ សត្ថា ឥធាគមិស្សតិ, មយំ តំ វន្ទិស្សាម, តស្ស ធម្មំ សុណិស្សាម ។ (ប្រែ) ស្វេ ក្នុងថ្ងៃស្អែក សត្ថា ព្រះជាគ្រូ អាគមិស្សតិ នឹងយាងមក ឥធ ឋានេ ក្នុងទីនេះ, មយំ យើងទាំងឡាយ វន្ទិស្សាម នឹងថ្វាយបង្គំ តំ នូវព្រះអង្គ, សុណិស្សាម នឹងស្តាប់ ធម្មំ នូវធម៌ តស្ស នៃព្រះអង្គ ។

(សម្ពន្ធ) សត្ថា សយកត្តា ក្នុង អាគមិស្សតិ ។ អាខ្យាតបទ កត្តុវាចក:, ស្វេ កាលសត្តមី ក្នុង អាគមិស្សតិ, ឥធ វិសេសន: របស់ ឋានេ ។ អាធារ: ក្នុង អាគមិស្សតិ, មយំ សយកត្តា ក្នុង វន្ទិស្សាម សុណិស្សាម ។ អាខ្យាតបទ កត្តុវាចក:, តំ អវុត្តកម្ម ក្នុង វន្ទិស្សាម, តស្ស សាមិសម្ពន្ធ: ក្នុង ធម្មំ ។ អវុត្តកម្ម ក្នុង សុណិស្សាម ។

"ត" ដែលប្រែថា "លោក" ឧ. មយ្ហំ ឧបជ្ឈាយោ បញ្ចាសីតិវស្សាយុកោ, សោ បន ទេវសិកំ តាវ កិច្ចសាម-លោកនំ បរិយត្តិធម្មំ វាចេតុំ សក្កោតិ ។ (ប្រែ) ឧបជ្ឈាយោ ឧបជ្ឈាយ៍ មយ្ហំ របស់ខ្ញុំ បញ្ចាសីតិវស្សាយុកោ មានព្រះជន្ម ៨៥ ឆ្នាំ

(ហើយ), បទ ប៉ុន្តែ សោ វិលោក សក្កោតិ តាច វាចេតុំ ដើម្បីបង្រៀន បរិយត្តិធម្មំ ឲ្យព្រះបរិយត្តិធម៌ ភិក្ខុសាមណេរានំ ដល់ភិក្ខុនិងសាមណេរទាំងឡាយ គាត់ បាននៅឡើយ ។

(សម្ពន្ធ) មយ្ហំ សាមិសម្ពន្ធៈ ក្នុង ឧបជ្ឈាយោ ។ លិង្គត្ថៈ, បញ្ចាសីតិវស្សាយុកោ វិសេសនៈ របស់ ឧបជ្ឈាយោ, បនស័ព្ទ សម្ភាវនវាចកៈ, សោ សយកត្តា ក្នុង សក្កោតិ ។ អាខ្យាតបទ កត្តុវាចកៈ, ទេវសិកំ កិរិយាវិសេសនៈ ក្នុង សក្កោតិ, តាវស័ព្ទ កិរិយាវិសេសនៈ ក្នុង សក្កោតិ, ភិក្ខុសាមណេរានំ សម្បទានៈ ក្នុង សក្កោតិ, បរិយត្តិធម្មំ អវុត្តកម្ម ក្នុង វាចេតុំ។ តុមន្តសម្បទានៈ ក្នុង សក្កោតិ ។

"តេ" ដែលប្រែថា "នាង" ។ វិសាខា មហាឧបាសិកា សទ្ធា អហោសិ ពុទ្ធសាសនេ អភិប្បសន្នា; តថា ច តស្សា បុត្តធីតរោ ។ (ប្រែ) មហាឧបាសិកា រីមហាឧបាសិកា វិសាខា ឈ្មោះវិសាខា សទ្ធា ជាស្ត្រីមានសទ្ធា អភិប្បសន្នា ជ្រះថ្លាក្រៃពេក ពុទ្ធសាសនេ ក្នុងព្រះពុទ្ធសាសនា អហោសិ បានមានហើយ; ច ឯ បុត្តធីតរោ រីកូនប្រុសនិងកូនស្រីទាំងឡាយ តស្សា របស់នាង តថា ក៏ដូច្នោះដែរ ។

(សម្ពន្ធ) មហាឧបាសិកា បកតិកត្តា ក្នុង អហោសិ ។ អាខ្យាតបទ

គុត្តបទៈ, វិសាខា សញ្ញាវិសេសនៈ របស់ មហាឧបាសិកា ។ សញ្ញី វិសេសយៈ, សទ្ធាត្តិ អភិប្យសទ្ទាត្តិ វិកតិកត្តា គុន អហោសិ, ពុទ្ធ-សាសនេ អាធារៈ គុន អភិប្យសទ្ទា; តថា បុរិមនយជោតកៈ, បសត្ថ វាក្យារម្ភជោតកៈ, តស្សា សាមិសម្ពន្ធៈ គុន បុគ្គលិកាពេ ។ លិង្គត្ថៈ ។

"តេ" ដែលប្រែថា "គេ" ថា "គាត់" ឧ. ឯកោ មហា-លុទ្ធកវត្ថុកី ឯកគាមវាសីនំ មនុស្សានំ បិយោ អហោសិ មនាបោ; សោ ហិ តេសំ ឧបការមកាសិ; តស្មឹ បន មតេ, សព្វេបិ តេ ឯកច្ឆន្ទា ហុត្វា សក្កច្ចំ តស្ស សរីរកិច្ចមកំសុ ។ (ប្រែ) មហាលុទ្ធកវត្ថុកី ជាង ឈើចាស់ ឯកោ ម្នាក់ បិយោ មនាបោ អហោសិ ជាទីស្រឡាញ់ពេញចិត្ត មនុស្សានំ នៃមនុស្សទាំងឡាយ ឯកគាមវាសីនំ អ្នកនៅក្នុងស្រុកជាមួយ; ហិ ព្រោះ សោ វីគាត់ អកាសិ បានធ្វើហើយ ឧបការំ នូវសេចក្តីទំនុកបំរុង តេសំ ដល់គេទាំងឡាយ; បន ក៏ តស្មឹ កាលដែលគាត់ មតេ ស្លាប់ហើយ, តេ វីគេទាំងឡាយ សព្វេបិ ទាំងអស់គ្នា ឯកច្ឆន្ទា ហុត្វា ជាអ្នកមានសេចក្តីពេញចិត្តតែមួយ អកំសុ បានធ្វើហើយ សរីរកិច្ចំ នូវសរីរកិច្ច តស្ស នៃគាត់ សក្កច្ចំ ដោយការយកចិត្តទុកដាក់ ។

(សម្ពន្ធ) ឯកោ វិសេសនៈ របស់ មហល្លកវល្លិកំ ។ បកតិកត្តា គុណ អរោហសិ ។ អាខ្យាតបទ កត្តុវាចកៈ, ឯកកាមកសីនំ វិសេសនៈ របស់ មនុស្សានំ ។ សាមិសម្ពន្ធៈ គុណ បរោយ មនាបោ ។ វិកតិកត្តា គុណ អរោហសិ; ហិស័ព្ទ ផលជោតកៈ, សោ សយកត្តា គុណ អកាសិ ។ អាខ្យា-តបទ កត្តុវាចកៈ, តេសំ សម្បទាន គុណ អកាសិ, ឧបការំ អវុត្តកម្ម គុណ អកាសិ; បនស័ព្ទ វាក្យារម្ភៈ, តស្មិំ លក្ខណៈ គុណ មតេ ។ លក្ខណកិរិយា, សត្ថេ វិសេសនៈ របស់ តេ ។ សយកត្តា គុណ អកំសុ ។ អាខ្យាតបទ កត្តុវាចកៈ, បិស័ព្ទ អបេក្ខត្ថៈ គុណ សត្ថេ, ឯកច្ចនា វិកតិកត្តា គុណ ហុត្វា ។ កិរិយាវិសេសនៈ គុណ អកំសុ, សក្កច្ចំ គតិយាវិសេសនៈ គុណ អកំសុ, តស្ស សាមិសម្ពន្ធៈ គុណ សរីរកិច្ចំ ។ អវុត្តកម្ម គុណ អកំសុ ។

“ត” ដែលប្រែថា “រ” ឧ. ឃរេតាវ មេ អវជាតបុត្តោ អត្ថិ, នេវ តំ ឱវាទំ គណ្ហាបេតុំ សក្កោមិ; ឥទានិ បន សោ ពាឡ្ហគិលានោ; សចេបិ មហាជេកោ មម គេ-ហំ អាគន្ត្វា តស្សោវាទំ ទស្សតិ; សោ តស្សោវាទេ បតិស្សតិ មញ្ញេ ។ (ប្រែ) “បុត្តោ” កូនប្រុស ឯកោ ម្នាក់ មេ របស់ខ្ញុំ អវជាតបុត្តោ ជាអវជាតបុត្រ អត្ថិ មាន; អហំ ខ្ញុំ នេវ សក្កោមិ មិនអាចនឹងពិត តំ ឱវាទំ គណ្ហាបេតុំ ដើម្បីញុំាងវាឲ្យកាន់

យកនូវទុក្ខ; បន ប៉ុន្តែ ឥទានិ គឺកាលឥឡូវនេះ សោ រីក ពាឡ្ហ-គិលានោ ឈឺធ្ងន់ណាស់; សចេបិ ប្រសិនបើ មហាថេរោ ព្រះមហាថេរ អាគន្ត្វា នឹងមកហើយ គេហំ កាន់ផ្ទះ មម របស់ខ្ញុំ ទស្ស-តិ នឹងឲ្យ ទុក្ខំ នូវទុក្ខ តស្ស ដល់ក; សោ រីក បស្សតិ ម-ញ្ញេ ប្រហែលជានឹងស្ថិតនៅ ទុក្ខេ គឺទុក្ខ តស្ស របស់លោក ។

(សម្ពន្ធ) ឯកោ វិសេសនៈ របស់ អវជាតបុត្តោ ។ សយកត្តា គឺ អត្ថិ ។ អាខ្យាតបទ កត្តុវាចកៈ, មេ សាមិសម្ពន្ធៈ គឺ អវជាតបុត្តោ; អហំ សយកត្តា គឺ សក្កោមិ ។ អាខ្យាតបទ កត្តុវាចកៈ; នសព្ទ បដិសេធនៈ គឺ សក្កោមិ, ឯវសព្ទ អវធារណៈ គឺ ន, តំ ការិតកម្ម គឺ គណ្ហាបេតុំ, ទុក្ខំ អវុត្តកម្ម គឺ គណ្ហាបេតុំ ។ តុមត្ថសម្បទាន គឺ សក្កោមិ; បនសព្ទ សត្តានត្ថៈ, ឥទានិ កាលសត្តមី គឺ សោ ។ លិង្គត្ថៈ, ពាឡ្ហគិលានោ វិសេសនៈ របស់ សោ, សចេសព្ទ បរិកប្បត្ថៈ, អបិសព្ទ អបេក្ខត្ថៈ គឺ សចេ, មហាថេរោ សយកត្តា គឺ ទស្សតិ ។ អាខ្យាតបទ កត្តុវាចកៈ, មម សាមិសម្ពន្ធៈ គឺ គេហំ ។ សម្បាបុណិយកម្ម គឺ អាគន្ត្វា ។ បុព្វកាលកិរិយា គឺ ទស្សតិ, តស្ស សម្បទាន គឺ ទស្សតិ, ទុក្ខំ អវុត្តកម្ម គឺ ទស្សតិ; សោ សយកត្តា គឺ បស្សតិ ។ អាខ្យាតបទ កត្តុវាចកៈ, តស្ស សាមិសម្ពន្ធៈ គឺ ទុក្ខេ ។

អាធារៈ ក្នុង បស្សតិ, មញ្ញេ សំសយត្ថៈ ក្នុង សោ ។

“តុម្ហ” ដែលប្រែថា “ព្រះអង្គ, លោក, អ្នក, នាង, ឯង, អា, ហែង” (តាមពាក្យខ្ពស់ កណ្ដាល និងទាប) ។

“តុម្ហ” ដែលប្រែថា “ព្រះអង្គ” ឧ. ភន្តេ កឹ តុម្ហេយេវ គមិស្សថ ។ (ប្រែ) ភន្តេ បពិត្រព្រះអង្គដ៏ចំរើន តុម្ហេ ឯវ ព្រះអង្គតែមួយព្រះអង្គឯង គមិស្សថ នឹងស្ដេចទៅ កឹ ឬ ?

(សម្ពន្ធ) ភន្តេ សគារវាលបនៈ, កឹសព្ទ បុច្ឆនត្ថៈ, តុម្ហេ សយកត្តា ក្នុង គមិស្សថ ៗ អាខ្យាតបទ កត្តុវាចកៈ, ឯវសព្ទ អវធារណៈ ក្នុង តុម្ហេ ។

“តុម្ហ” ដែលប្រែថា “លោក” ឧ. ភន្តេ តុហឹ តុម្ហេ គមិស្សថ ។ (ប្រែ) ភន្តេ បពិត្រលោកម្ចាស់ដ៏ចំរើន តុម្ហេ លោក គមិស្សថ នឹងនិមន្តទៅ តុហឹ ក្នុងទីណា ?

(សម្ពន្ធ) ភន្តេ សគារវាលបនៈ, តុម្ហេ សយកត្តាក្នុងគមិស្សថ ៗ អាខ្យាតបទកត្តុវាចកៈ, តុហឹ វិសេសនៈ របស់ ឋានាធារៈ ក្នុង គមិស្សថ ។

“តុម្ហ” ដែលប្រែថា “អ្នក” ឧ. អាវុសោ តុំ មា ឯវំ ចិន្តយិ ។ (ប្រែ) អាវុសោ ម្នាលអាវុសោ តុំ អ្នក មា ចិន្តយិ កុំគិត ឯវំ យ៉ាងនេះឡើយ ។

(សម្ពន្ធ) អាវុសោ អគារវាលបនៈ, តុំ សយកត្តា ក្នុង ចិន្តយិ ៗ

អាខ្យាតបទ កត្តុវាចក:, មាសព្ទ បដិសេធន: ក្នុង ចិន្តយិ, ឯវំ កិរិយាវិ-សេសន: ក្នុង ចិន្តយិ ។

“តុម្ហ” ដែលប្រែថា “នាង” ឧ. សចេ ហិ តុម្ហេ មាទិសស្ស ពុទ្ធស្ស សម្មុខីភាវំ នាគមិស្សថ ។ (ប្រែ) សចេ ហិ ប្រសិនបើ តុម្ហេ នាងទាំងឡាយ ន អាគមិស្សថ ទើនមិនមកហើយ សម្មុខីភាវំ កាន់ភាវៈចំពោះមុខ ពុទ្ធស្ស នៃព្រះពុទ្ធ មាទិសស្ស ប្រាកដដូចជាតថាគត ។

(សម្ពន្ធ) សចេសព្ទ បរិកប្បត្ថជោតក:, ហិសព្ទ បទបូរណ:, តុម្ហេ សយកត្តា ក្នុង អាគមិស្សថ ។ អាខ្យាតបទ កត្តុវាចក:, មាទិសស្ស វិសេសន: របស់ ពុទ្ធស្ស ។ ភាវាទិសម្ពន្ធ: ក្នុង សម្មុខីភាវំ ។ សម្បាបុណិយកម្ម ក្នុង អាគមិស្សថ, នសព្ទ បដិសេធន: ក្នុង អាគមិស្សថ ។

“តុម្ហ” ដែលប្រែថា “ឯង” ឧ. អរេ ឥតោ តាវ ត្វំ ឯហិ (ប្រែ) អរេ នែអាចង្រៃ ត្វំ ឯង ឯហិ ចូរមក ឥតោ ត្រង់នេះ តាវ សិន ។

(សម្ពន្ធ) អរេ អាលបន:, ត្វំ សយកត្តា ក្នុង ឯហិ ។ អាខ្យាតបទ កត្តុវាចក:, ឥតោ អាធារ: ក្នុង ឯហិ, តាវសព្ទ កិរិយាវិសេសន: ក្នុង ឯហិ ។

“តុម្ហ” ដែលប្រែថា “អា” ឧ. អរេ ទុដ្ឋកាដ្ឋិ កឹ ត្វំ វេធសិ ? មាទិសា ខុជ្ជា នាម ហោតិ ។ (ប្រែ) ទុដ្ឋកាដ្ឋិ

នៃអាត់លង់កំណាច អរេ ចង្រៃ ត្វំ ឯង វទេសិ ពោល កឹ ជាម៉េច? មា-ទិសា ស្ត្រីអំបាលដូចជាអញ ខុជ្ជា នាម ហោតិ (ហៅថា) ជាស្ត្រីគមៗ

(សម្ពន្ធ) អរេ វិសេសនៈ របស់ ខុជ្ជេៗ អាលបនៈ, ត្វំ សយកត្តា ក្នុង វទេហិ អាខ្យាតបទ កត្តុវាចកៈ, កឹ វិសេសនៈ របស់ វទេសិ, មាទិសា បកតិកត្តា ក្នុង ហោតិ អាខ្យាតបទ កត្តុវាចកៈ, ខុជ្ជា វិកតិកត្តា ក្នុងហោតិ, នាមសព្ទ សញ្ញាជោតកៈ ក្នុង ខុជ្ជា ។

“តុម្ហ” ដែលប្រែថា “ឯង” ឧ. អរេ ខុជ្ជេ អតិពហលោដ្ឋករោចាលំ តេ មុខំ, ឯវំ នាម (ត្វំ) វទេហិ ។ (ប្រែ) អរេ ខុជ្ជេ នែមេគមចង្រៃ មុខំ មាត់ តេ នៃឯង អតិពហលោដ្ឋករោចាលំ មានបបូរក្រាស់ឃ្មឹកពេកណាស់, ត្វំ ឯង វទេហិ ចូរថា ឯវំ នាម យ៉ាងនេះវិញ ។

(សម្ពន្ធ) អរេ វិសេសនៈ របស់ ខុជ្ជេៗ អាលបនៈ, អតិពហលោដ្ឋករោចាលំ វិសេសនៈ របស់ មុខំ, តេ សាមិសម្ពន្ធៈ ក្នុង មុខំៗ លិង្គត្ថៈ; ត្វំ សយកត្តា ក្នុង វទេហិ អាខ្យាតបទ កត្តុវាចកៈ, ឯវំ កិរិយាវិសេសនៈ ក្នុង វទេហិ, នាមសព្ទ សញ្ញាជោតកៈ ក្នុង ឯវំ ។

“អម្ហ” សព្ទ ប្រែថា “ខ្ញុំព្រះអង្គ, ខ្ញុំព្រះករុណា, ខ្ញុំបាទ; ខ្ញុំឯង, អញខ្ញុំ, ខ្ញុំម្ចាស់, ខ្ញុំ, អាត្មាភាព, អាត្មា, អញ, យើង, យើងខ្ញុំ” ។

«អម្ហ» ដែលប្រែថា «ខ្ញុំព្រះអង្គ» ឧ. ឧបជ្ឈាយោ មេ ភន្តេ បំសុកូលិកោ, ឃរិ អហំ បិ បំសុកូលិកោ ។ (ប្រែ) ភន្តេ បពិត្រព្រះអង្គដ៏ចំរើន ឧបជ្ឈាយោ រីព្រះឧបជ្ឈាយ៍ មេ របស់ខ្ញុំព្រះអង្គ បំសុកូលិកោ ហោតិ ជាអ្នកប្រព្រឹត្តបង្សុកូល, បិ ក៏ អហំ រីខ្ញុំព្រះអង្គ បំសុកូលិកោ អម្ហិ ជាអ្នកប្រព្រឹត្តបង្សុកូល ឯវំ យ៉ាងនេះដែរ ។

(សម្ពន្ធ) ភន្តេ សគារវាលបនៈ, ឧបជ្ឈាយោ បកតិកត្តា ក្នុង ហោតិ ៗ អាខ្យាតបទ កត្តុវាចកៈ, មេ សាមិសម្ពន្ធៈ ក្នុង ឧបជ្ឈាយោ, បំសុកូលិកោ វិកតិកត្តា ក្នុង ហោតិ; អហំ បកតិកត្តា ក្នុង អម្ហិ ៗ អាខ្យាតបទ កត្តុវាចកៈ, ឯវំ កិរិយាវិសេសនៈ ក្នុង អម្ហិ, បិសព្ទ អបេក្ខត្ថៈ ក្នុង អហំ, បំសុកូលិកោ វិកតិកត្តា ក្នុង អម្ហិ ៗ អាខ្យាតបទ កត្តុវាចកៈ ។

«អម្ហ» ដែលប្រែថា «ខ្ញុំព្រះករុណា» ឧ. ឯសាហំ ភន្តេ តំ ភគវន្តំ សរណំ គច្ឆាមិ ធម្មញ្ច ភិក្ខុសង្ឃញ្ច; ឧបាសកំ មំ អយ្យោ ធារេតុ អជ្ជតគ្គេ បាណុបេតំ សរណំ គតំ ។ (ប្រែ) ភន្តេ បពិត្រព្រះអង្គដ៏ចំរើន អហំ រីខ្ញុំព្រះករុណា ឯសោ នេះ គច្ឆាមិ សូមដល់ តំ ភគវន្តំ ច នូវព្រះដ៏មានព្រះភាគនោះផង ធម្មំ ច នូវព្រះធម៌ផង ភិក្ខុសង្ឃំ ច នូវព្រះភិក្ខុសង្ឃផង សរណំ ជាទីពឹងទីរឭក; អយ្យោ រីលោកម្ចាស់ ធារេតុ សូមចាំទុក មំ

នូវខ្ញុំព្រះករុណា ។ ឧបាសកំ ជាឧបាសក បាណុបេតំ ដល់នូវព្រះត្រៃស-សរណៈស្មើដោយជីវិត អជ្ជតគ្គេ ក្នុងកាលមានថ្ងៃនេះជាដើមតទៅ ។

(សម្ពន្ធ) ភន្តេ សត្ថាលបនៈ, ឯសោ វិសេសនៈ របស់ អហំ ។ សយកត្តា ក្នុង គច្ឆាមិ ។ អាខ្យាតបទ កត្តុវាចកៈ, តំ វិសេសនៈ របស់ ភគវន្តំ ។ ក្តី ធម្មំក្តី ភិក្ខុសង្ឃំក្តី បកតិអវុត្តកម្ម ក្នុង គច្ឆាមិ, សរណំ វិក-តិអវុត្តកម្ម ក្នុង គច្ឆាមិ, ច ចាំងពីរបទ បទសមុច្ចយ ក្នុង ធម្មំ ភិក្ខុសង្ឃំ; អាយស្មា សយកត្តា ក្នុង ធារេតុ ។ អាខ្យាតបទ កត្តុវាចកៈ, មំ បកតិអវុត្ត-កម្ម ក្នុង ធារេតុ, ឧបាសកំ វិកតិអវុត្តកម្ម ក្នុង ធារេតុ, បាណុបេតំក្តី សរ-ណំក្តី គតំក្តី វិសេសនៈ របស់ មំ, អជ្ជតគ្គេ កាលសត្តមី ក្នុង ធារេតុ ។

“អម្ហ” ដែលប្រែថា “ខ្ញុំឯង” ឧ. អហាមេវ នូន ពា-លោ ហោមិ ។ (ប្រែ) អហំឯង ខ្ញុំឯង ពាលោហោមិ ជាជន-ពាល នូន ដោយពិត ។

(សម្ពន្ធ) អហំ បកតិកត្តា ក្នុង ហោមិ ។ អាខ្យាតបទ កត្តុវាចកៈ, ឯវ សព្ទ អវធារណៈ ក្នុង អហំ, នូន កិរិយាវិសេសនៈ ក្នុង ហោមិ, ពាលោ វិកតិកត្តា ក្នុង ហោមិ ។

“អម្ហ” ដែលប្រែថា “ខ្ញុំម្ចាស់” ឧ. ទេវ សរេច មេ ន សទ្ទហាសិ, ឃតំ គោដ្ឋកំ បវិស: អហាត្តិ ឥ-

មិនា វាតបានេន ឱលោកេស្សាមិ ។ (ប្រែ) ទេវ បពិត្រព្រះសម្មតិទេព បេ បើ ត្វំ រីព្រះអង្គ ន សទ្ទហសិ ទ្រង់ពុំជឿ (ចំពោះនូវពាក្យ) មេ នៃខ្ញុំម្ចាស់, ត្វំ រីព្រះអង្គ បវិស សូមស្តេចយាងចូល គោដ្ឋកំ កាន់បន្ទប់ ឯកំ មួយ; អហំ រីខ្ញុំម្ចាស់ ឱលោ-កេស្សាមិ នឹងចាំមើល តំ នូវព្រះអង្គ វាតបានេន តាមព្រះកៅរកា (កក់តា) ឥមិនា នេះ ។

(សម្ពន្ធ) ទេវ អាលបនៈ, សចេសព្ទ បរិកប្បត្ថៈ, ត្វំ សយកត្តា ក្នុង សទ្ទហសិ ។ អាខ្យាតបទ កត្តុវាចកៈ, មេ សាមិសម្ពន្ធៈ ក្នុង វចនំ ។ អវុត្តកម្ម ក្នុង សទ្ទហសិ នសព្ទ បដិសេធនៈ ក្នុង សទ្ទហសិ, ត្វំ សយកត្តា ក្នុង បវិស ។ អាខ្យាតបទ កត្តុវាចកៈ, ឯកំ វិសេសនៈ របស់ គោដ្ឋកំ ។ សម្បា-បុណិយកម្ម ក្នុងបវិស; អហំ សយកត្តា ក្នុង ឱលោកេស្សាមិ ។ អាខ្យាតបទ កត្តុវាចកៈ, តំ អវុត្តកម្ម ក្នុង ឱលោកេស្សាមិ, ឥមិនា វិសេសនៈ របស់ វាតបានេន ។ វិសេសនត្តតិយា ក្នុង ឱលោកេស្សាមិ ។

“អម្ហ” ដែលប្រែថា “ខ្ញុំ” ឧ. ឥច្ឆាមហំ អម្ម ថេរស្ស សន្តិកេ បព្វជិតុំ ។ (ប្រែ) អម្ម បពិត្រអ្នកម្តាយ អហំ រីខ្ញុំ ឥច្ឆាមិ ចង់ បព្វជិតុំ ដើម្បីបួស សន្តិកេ ក្នុងសំណាក់ ថេរស្ស នៃព្រះថេរៈ ។

(សម្ពន្ធ) អម្ហ សគារវលបនៈ, អហំ សយកត្តា ក្នុង ឥច្ឆាមិ ។ អាខ្យាតបទ កត្តុវាចកៈ, ថេរស្ស សាមិសម្ពន្ធៈ ក្នុង សន្តិកេ ។ សេយ្យ-ការកៈ ក្នុង បព្វជិតុំ ។ តុមត្ថសម្បទាន ក្នុង ឥច្ឆាមិ ។

"អម្ហ" ដែលប្រែថា "អាត្មាភាព" ឧ. តេនហិ មហារាជ អហំ តញ្ញេវេត្ថ បដិបុច្ឆិស្សាមិ ។ (ប្រែ) មហារាជ បពិត្រមហារាជ តេនហិ បើដូច្នោះ អហំ អាត្មាភាព បដិបុច្ឆិស្សាមិ នឹងសូមថ្វាយព្រះពរសួរត្រឡប់ តំ នូវព្រះអង្គវិញ ឯត្ថ បញ្ហេ ក្នុងប្រស្នា-នេះ ។

(សម្ពន្ធ) មហារាជ សគារវលបនៈ, តេនហិ វិភត្តិបដិរូបកៈ, អហំ សយកត្តា ក្នុង បដិបុច្ឆិស្សាមិ ។ អាខ្យាតបទ កត្តុវាចកៈ, តំ អវុត្តកម្ម ក្នុង បដិបុច្ឆិស្សាមិ, ឯវសទ្ទ អវធារណៈ ក្នុង តំ, ឯត្ថ វិសេសនៈ របស់ បញ្ហេ ។ អាធារៈ ក្នុង បដិបុច្ឆិស្សាមិ ។

"អម្ហ" ដែលប្រែថា "អាត្មា" ឧ. អហំ ថេរស្ស ភាគិនេ-យ្យោម្ហិ ។ (ប្រែ) អហំ អាត្មា ភាគិនេយ្យោ អម្ហិ ជាក្មួយ ថេរស្ស នៃព្រះថេរៈ ។

(សម្ពន្ធ) អហំ បកតិកត្តា ក្នុង អម្ហិ ។ អាខ្យាតបទ កត្តុវាចកៈ, ថេរស្ស សាមិសម្ពន្ធៈ ក្នុង ភាគិនេយ្យោ ។ វិកតិកត្តា ក្នុង អម្ហិ ។

"អម្ហ" ដែលប្រែថា "អញ" ឧ. នាហំ មម បុត្តស្ស អជ្ឈាសយំ ភិន្ទិស្សាមិ ។ (ប្រែ) អហំ អញ នភិន្ទិស្សាមិ នឹងមិនទំលាយ អជ្ឈាសយំ នូវអធ្យាស្រ័យ បុត្តស្ស នៃកូន មម របស់អញ ។

(សម្ពន្ធ) អហំ សយកត្តា ក្នុង ភិន្ទិស្សាមិ ។ អាខ្យាតបទ កត្តុវាចក: មម សាមិសម្ពន្ធ: ក្នុង បុត្តស្ស ។ សាមិសម្ពន្ធ: ក្នុង អជ្ឈាសយំ ។ អវុត្តកម្ម ក្នុង ភិន្ទិស្សាមិ ។

"អម្ហ" ដែលប្រែថា "យើង" ឧ. មហល្លកកាលេ បព្វជិតា មយំ ។ (ប្រែ) មយំ យើង បព្វជិតា បួសហើយ មហល្លកកាលេ ក្នុងកាលដែលយើងចាស់ ។

(សម្ពន្ធ) មហល្លកកាលេ កាលសត្តមី ក្នុង បព្វជិតា ។ វិសេសន: របស់ មយំ ។ លិង្គត្ថ: ។

២) បើជាវិសេសនសព្វនាម សម្ពន្ធដូចគុណនាម តាំងនិយម: តាំងអនិយម:

ឧ. យស្មិំ ភគវតិ មយំ អភិប្បសន្នា, តំ ភគវន្តំ សរណំ គតា ។ (ប្រែ) មយំ យើងទាំងឡាយ អភិប្បសន្នា ជ្រះថ្លាហើយក្រៃពេក ភគវតិ ក្នុងព្រះដ៏មានព្រះភាគ យស្មិំ អង្គណា,

មយំ ពួកយើងទាំងឡាយ គតា ដល់ហើយ ភគវន្តំ នូវព្រះដ៏មានព្រះភាគ តំ អង្គនោះ សរណំ ជាទីពឹង ។

(សម្ពន្ធ) មយំ សយកត្តា ក្នុង អភិព្យសង្ខា ។ កិតបទ កត្តុវាចក:, យស្មិំ វិសេសន: របស់ គតវិត ។ អាធារ: ក្នុង អភិព្យសង្ខា; មយំ សយកត្តា ក្នុង គតា ។ កិតបទ កត្តុវាចក:, តំ វិសេសន: របស់ ភគវន្តំ ។ បកតិអវុត្តកម្ម ក្នុង គតា, សរណំ វិកតិអវុត្តកម្ម ក្នុង គតា ។

យោ បន ភិក្ខុ សមគ្គស្ស សង្ឃស្ស ភេទាយ បរក្កមេយ្យ, ភេទនសំវត្តនិកំ វា អធិករណំ សមាទាយ បគ្គយ្ហ តិដ្ឋេយ្យ, សោ ភិក្ខុ ភិក្ខូហិ ឯវមស្ស វចនីយោ ។ (ប្រែ) យោ បន ភិក្ខុ ភិក្ខុណាមួយ បរក្កមេយ្យ ព្យាយាម ភេទាយ ដើម្បីបំបែក សង្ឃស្ស នូវសង្ឃ សមគ្គស្ស ដែលកំពុងព្រមព្រៀងគ្នា, វា ឬថា សមាទាយ ប្រកាន់ហើយ បគ្គយ្ហ ផ្គងឡើងហើយ អធិករណំ នូវអធិករណ៍ ភេទនសំវត្តនិកំ ដែលដឹកនាំសង្ឃឲ្យបែកគ្នា តិដ្ឋេយ្យ គប្បីស្ថិតនៅ, ភិក្ខុ រីភិក្ខុ សោ នោះ ឯវំ ភិក្ខូហិ វចនីយោ អស្ស ជាបុគ្គលត្រូវភិក្ខុទាំងឡាយពោលហាម ដោយពាក្យយ៉ាងនេះ ។

(សម្ពន្ធ) យោ វិសេសន: របស់ ភិក្ខុ ។ សយកត្តា ក្នុង បរក្កមេយ្យ

